# សហភាពអឺរ៉ុបផ្តល់បរិក្ខារសង្កេតការណ៍បោះឆ្នោតដល់អង្គការ សេដាក

សហភាពអឺរ៉ុបបានសម្រេចចិត្តផ្តល់គ្រឿងបរិក្ខារដែលប្រើប្រាស់ដោយក្រុមសង្កេតការណ៍បោះឆ្នោតសហភាពអឺរ៉ុប នាពេលថ្មីៗនេះរួមមាន កុំព្យូទ័រយួរដៃ ទូរស័ព្ទចល័ត បរិក្ខារ និងសម្ភារៈការិយាល័យផ្សេងៗ ជូនដល់ អង្គការ សេដាក ក៏ដូចជាអង្គការសង្គមស៊ីវិលចំនួន១៦ ផ្សេងទៀតដែលមានតម្លៃសរុបចំនួន ១៣០.០០០ អឺរូ (ជាង១៨០.០០០ដុល្លារ) ដើម្បីយកទៅប្រើប្រាស់ទៅតាមតម្រូវការតាមស្ថាប័ននីមួយៗ ។

ពិធីប្រគល់ និងទទួលនេះ ធ្វើឡើងកាលពីព្រឹកថ្ងៃទី២៧ ខែសីហា រវាងលោក Rafael Dochao Moreno ភារធារីនៃប្រតិភូគណៈកម្មការសហគមន៍អឺរ៉ុបប្រចាំនៅកម្ពុជា និងប្រធាន និងតំណាងអង្គការ សង្គមស៊ីវិលទាំង ១៧ នៅឯសណ្ឋាគារកាំបូឌីយ៉ាណា ។

លោក Rafael Dochao Moreno មានប្រសាសន៍ឱ្យដឹងថា "ខ្ញុំមានសេចក្តីរំភើបរីករាយឥតឧបមា ដែលបានជួយឧបត្ថម្ភគាំទ្រដល់អង្គការមិនមែនរដ្ឋាភិបាលកម្ពុជាតាមមធ្យោបាយនេះ ។ លោក ភារធារី បានមានប្រសាសន៍ទៀតថា "សហភាពអឺរ៉ុបគឺជាឧបត្ថម្ភគាំទ្រដ៏ធំជាងគេបំផុតដល់អង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា ហើយខ្ញុំជឿជាក់ថាគ្រឿងបរិក្ខាទាំងនេះនឹងជួយដល់ការងាររបស់អង្គការ មិនមែនរដ្ឋាភិបាលកម្ពុជាបន្ថែមទៀតដូចជា ការអប់រំប្រជាពលរដ្ឋអំពីសិទ្ធិ និងករណីកិច្ចរបស់ពួកគេការធ្វើជាតំណាងរបស់ក្រុមងាយរងគ្រោះ និងជាទូទៅការបង្កើនការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចសង្គម និងប្រជាធិបតេយ្យនៃប្រទេសកម្ពុជា" ។

ដោយឡែក អង្គការ សេដាក ដែលតំណាងដោយលោក **អ៊ូច ង៉ាក់** បានទទួលបរិក្ខារពីសគមន៍អ៊ឺរ៉ុប ហើយគ្រោងនឹងធ្វើការបែងចែកទៅឱ្យបុគ្គលិកនៅតាមតំបន់គោលដៅទូទាំង ២១ ខេត្តក្រុង។